# បើយើងចេះប្រមូលទុនទ្រទ្រង់សមាគម
# យើងនឹងបានទុនសម្រាប់ទ្រទ្រង់...

ថ្ងៃទី ១៨-១៩ ខែតុលា ឆ្នាំ២០១១ បណ្តាញកសិករ និងធម្មជាតិសហការជាមួយអង្គការសេដាក បានរៀបចំសិក្ខាសាលាមួយ នៅការិយាល័យកណ្តាលអង្គការសេដាករាជធានីភ្នំពេញ ដោយបានអញ្ជើញអ្នកជំហរការងារសន្សំនៅតាមមូលដ្ឋាន ចំនួន ១០ ខេត្ត ដែលមានអ្នក ចូលរួមសរុប ៣១ នាក់ ។ គោលបំណងនៃសិក្ខាសាលានេះគឺ:

- ចែករំលែកភាពរីកចម្រើន ជាពិសេសធ្វើការវិភាគពីស្ថានភាពកើតដំបូង, ស្ថានភាពបច្ចុប្បន្ន និងផែនការ ៥ ឆ្នាំទៅមុខ សម្រាប់ការងារសន្សំប្រាក់នៅតាមមូលដ្ឋាន
- ពិគ្រោះយោបល់បង្កើតសមាគមសន្សំថ្នាក់ខេត្ត និងថ្នាក់ជាតិ
- គំនិតសំខាន់ៗមួយចំនួនទាក់ទងការងារអភិវឌ្ឍន៏ដែលអាស្រ័យខ្លួនឯង ឬអភិវឌ្ឍន៏ដែលកសិករជាម្ចាស់
- ផែនការតាមខេត្តដែលត្រូវអនុវត្តពេលត្រឡប់ទៅវិញ។

តាមរយ:សិក្ខាសាលានេះ យើងទទួលបានផ្លែផ្កាជាច្រើន នៅពេលនេះ ខ្ញុំសូមទាញនូវចំណុចពិសេសមួយតាមរយ:លទ្ធផលនៃការចែករំលែក ភាពរីកចម្រើនទាក់ទងទុនទ្រទ្រង់សមាគម ។ ខ្ញុំសង្កេតឃើញសមាគមចំនួន ៦ មកពីខេត្តកំពត, ព្រៃវែង, កំពង់ស្ពឺ និងខេត្តតាកែវ មានទុនទ្រទ្រង់សមាគមចាប់ពី ១០ លានរៀលឡើង សមាគមទាំង នេះមានដូចខាងក្រោម:



១. ***សមាគមសាមគ្គីសង្គ្រោះ*** មានទុនសន្សំសរុប ២២,៥លានរៀល មានសមាជិកសរុបចំនួន ៦២៦ នាក់ នៅក្នុងនោះយើងឃើញថា ***ទុនទ្រទ្រង់សមាគមសរុបចំនួន ៤០ លានរៀល (ទុន និងឧបករណ៏សម្ភារ:)*** ។ ប្រធាន សមាគមនេះឈ្មោះ ម៉ៅ ថាត់ អាយុ ៥៧ ឆ្នាំ គាត់រស់ នៅភូមិពងសត្វ ឃុំពងសត្វ ស្រុកឈូក ខេត្តកំពត សមាគមនេះកើតឡើងនៅថ្ងៃទី ៦ ខែមេសា ឆ្នាំ២០០០ សមាគមមានអាណត្តិ ៤ឆ្នាំ គាត់ជាប់ជាប្រធានសមាគម អាណត្តិទី ៣ ។ គាត់បញ្ជាក់ថា *ទុនទ្រទ្រង់សមាគមសំខាន់ណាស់ ពីព្រោះវាជួយទ្រទ្រង់ រចនាសម្ព័ន្ធសមាគមឲ្យដំណើរ ការល្អនិងជួយដល់ការកសាងសហគមន៏ឲ្យមានភាពរីកចម្រើន។*

២. *សមាគមក្តីសង្ឃឹម* មានទុនសន្សំសរុប ១ ៣៥០ លានរៀល មានសមាជិក ១៦៦ នាក់ ។ សមាគមបានរៀបចំឲ្យមាន*ទុនទ្រទ្រង់សមាគមចំនួន ២៧ លានរៀល* ។ ប្រធានសមាគម នេះជាស្ត្រី គឺអ្នកស្រី សោ សាមឿន អាយុ ៥៥ ឆ្នាំ រស់នៅភូមិកន្ទ្វែងជ្រៅ ឃុំក្របៅ ស្រុកកំចាយមា ខេត្តព្រៃវែង។ *គាត់បញ្ជាក់ថាទុនសមាគមមានប្រយោជន៍ណាស់ ដើម្បីឲ្យសមាគម ដំណើរការទៅមុខបានវែងឆ្ងាយ គណកម្មាការត្រូវបេះប្រមូលទុនសម្រាប់ ទ្រទ្រង់សមាគមឲ្យ ដំណើរការទៅមុខ ទុននេះមួយចំណែកជួយដល់គណកម្មាការ សមាគម, កាងារចំណាយ លើការប្រជុំ, ការចំណាយលើការអភិវឌ្ឍន៍ភូមិ និងជួយ សង្គ្រោះដល់អ្នកខ្វត់ខ្សោយក្នុងភូមិ*។ សមាគមនេះកើតឡើងនៅថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០០៩។



៣. *សមាគមរីករាយ ភូមិចារ* មានទុនសន្សំសរុបជាង ៦៨០ លានរៀល សមាជិកសន្សំមាន ៣៤៦ នាក់ ។ *ទុនទ្រទ្រង់សមាគមមានជាង ១៥ លានរៀល* ។ ប្រធានសមាគម ឈ្មោះ រៀប នី អាយុ ៥៨ ឆ្នាំ គាត់រស់នៅភូមិចារ ឃុំរលេច ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង។ *គាត់បញ្ជាក់ថា ទុនទ្រទ្រង់សមាគមជួយសមាជិក និងសហគមន៍បាន ច្រើនបើយើងបេះប្រមូល យើងនឹងបានទុនសម្រាប់ ទ្រទ្រង់សមាគមឲ្យ ដំណើរការទៅមុខដោយខ្លួនឯងដោយ មិនចាំបាច់ ប្រើប្រាស់ទុនពីខាងក្រៅឡើយ ។ ទុននេះ ប្រើប្រាស់សម្រាប់ប្រជុំ, ទ្រទ្រង់គណៈកម្មការ, ការងារអភិវឌ្ឍន៍ជាដើម* ។ សមាគមកើតឡើងនៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០០៥ ។



៤. *សមាគមពន្លឺពេជ្រ ភូមិព្រៃកំពោង* ។ មានទុនសន្សំសរុប ៩០ លានរៀល ។ សមាជិក សន្សំ ៦២ នាក់។ *ទុនទ្រទ្រង់សមាគមមានចំនួន ១១ លានរៀល*។ ប្រធានសមាគម ឈ្មោះ គុជ សាន អាយុ ៥០ ឆ្នាំ គាត់រស់នៅភូមិ ព្រៃកំពោង ឃុំកាហែង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។ *គាត់សង្កត់ធ្ងន់ថា ទុនទ្រទ្រង់សមាគមជួយឲ្យគណកម្មាការ ចុះ*



*ពង្រឹងក្រុមសន្សំនៅភូមិផ្សេងៗបាន ជាពិសេសថ្លៃធ្វើ ដំណើរ និងការងារជាប្រយោជន៍រួម។ គាត់សង្ឃឹមថា ទុន ទ្រទ្រង់នេះនឹងកើនថែមទៀត ទុកសម្រាប់សង់អាគារសមាគម ប្រជុំប្រចាំខែ* ។ សមាគមនេះកើតថ្ងៃទី១៨ ខែសីហា ឆ្នាំ ២០០៥ ។



៥. ***សមាគមពន្លឺកសិកររមន់*** មានទុនសន្សំសរុប ៣៧៥ លានរៀល មានសមាជិកសរុប ១៤៦ នាក់។ ***ទុនទ្រទ្រង់មាន ១០ លានរៀល*** ។ បងប្រុស សំម៉ក អាយុ ៥០ ឆ្នាំ រស់នៅភូមិរមន់ ឃុំបឹងត្រាញ់ខាងជើង ស្រុកសំរោង ខេត្តតាកែវ ជាបេឡាករសមាគម ***បានឲ្យដឹងថា ទុនទ្រទ្រង់ គឺពិតជាសំខាន់ជួយឲ្យសមាគមបន្តសកម្មភាពការងារអភិវឌ្ឍន៍ដោយខ្លួនឯង ពេលយើងចង់ធ្វើអ្វីយើងមានទុនត្រៀមជាស្រេចមិនលំបាកអ្វីទេឲ្យតែជាផលប្រយោជន៍រួមរបស់សមាជិក***។ សមាគមកើតនៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៥ ។



៦. ***សមាគមកសិករសំបូរផល*** មានទុនសន្សំសរុប ៩៤១ លានរៀល សមាជិកសន្សំសរុប ៥៥៣ នាក់ ។ ***ទុនទ្រទ្រង់ មានចំនួន ១០ លានរៀល***។ ប្រធានសមាគមឈ្មោះ អ៊ុង ទូច អាយុ ៥១ ឆ្នាំ ។ គាត់រស់នៅភូមិឫស្សីសាញ់ ឃុំ ឫស្សីសាញ់ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង ។ ***គាត់បង្ហាញថា ទុនទ្រទ្រង់សមាគមពិតជាសំខាន់ គណកម្មការ សមាគមត្រូវដើរតួនាទីជួយឲ្យមានទុនទ្រទ្រង់ និងប្រើប្រាស់ ទុនប្រកបដោយតម្លាភាព និងធានានូវផលប្រយោជន៍រួម***។ សមាគមនេះកើតនៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៦ ។

តាមរយៈការចែករំលែកពីសមាគមទាំង ៦ មក ខ្ញុំសូមធ្វើការបូកសរុបនូវចំណុចសំខាន់ៗ នៃផលប្រយោជន៍ទុនទ្រទ្រង់ដូចខាងក្រោម:

១- ជួយដល់អ្នកដឹកនាំសមាគមក្នុងការចុះទៅពង្រឹងសមាជិក, ចូលរួមប្រជុំ, ចូលរួមវគ្គ បណ្ដុះបណ្ដាល ជាពិសេសថ្លៃធ្វើដំណើរ និងថ្លៃអាហារប្រចាំថ្ងៃ។

២- ចំណាយលើថ្លៃរដ្ឋបាលដូចជា បញ្ជី, ក្រដាស និងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ

៣~ ចំណាយប្រជុំប្រចាំឆ្នាំ និងប្រជុំប្រចាំខែដូចជា ថ្លៃអាហារ, អាហារសម្រន់ ជាដើម។
៤~ សាងសង់អាគារប្រជុំ, សង្គ្រោះអ្នកក្រីក្រ, អភិវឌ្ឍន៍ជាដើម។

សូមបញ្ជាក់ថាទោះបីសមាគមមានទុនសន្សំច្រើនយ៉ាងណា យើងមិនអាចដកទុនសន្សំរបស់សមាជិកមកចំណាយបានទេ, តែយើងអាចដកប្រាក់ទ្រព្យមកចំណាយ ដើម្បីផលប្រយោជន៍រួម។ បច្ចុប្បន្ននេះយើងសង្កេតឃើញថានៅប្រទេសកម្ពុជាមានអង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធជាច្រើនបានចូលរួមក្នុងការជួយរៀបចំឲ្យមានរបទាសម្ព័ន្ធនៅតាមមូលដ្ឋាន ដែលសង្ឃឹមថា ពេលចប់កម្មវិធីរបស់ខ្លួន របទាសម្ព័ន្ធនៅតាមមូលដ្ឋាននឹងជួយបន្តសកម្មភាព ការងារអភិវឌ្ឍន៍ ដូច្នេះការជួយជម្រុញឲ្យសមាគមកសិករមានទុនទ្រព្យ និងប្រើប្រាស់ឲ្យមានប្រសិទ្ធ~ភាពដែលជាប្រយោជន៍ពិត។ របស់អ្នកមូលដ្ឋានគឺជាគុណតម្លៃដ៏ឧត្តុង្គឧត្តម។

ខ្ញុំសង្កេតឃើញថាសមាគមទាំង ៦ ខាងលើ អាចប្រមូលទុនទ្រព្យបានច្រើនសម្រាប់សមាគមចាប់ផ្តើមដំបូងដោយឲ្យសមាជិកបង់សមាជិកភាពប្រចាំឆ្នាំ ឬ និង បង់ជាស្រូវពេលប្រមូលផលប្រចាំឆ្នាំ។ ពេលសមាគមរីកចម្រើន គាត់បានផ្លាស់ប្តូរ ពីការបង់សមាជិកភាពប្រចាំឆ្នាំទៅជាការកាត់ប្រាក់ពីប្រាក់ចំណេញ ដោយគិតជាភាគរយ ចូលក្នុងទុនទ្រព្យសមាគមវិញ។ ជាបន្តបន្ទាប់គាត់យកប្រាក់ទាំងនោះទៅវិនិយោគ (ធ្វើជំនួញបន្តដូចជា ទិញរោងបុណ្យ ឬរោងការ មេក្រូ, តុ កៅអី ទុកសម្រាប់ជួល)។ ជាងនេះទៀតទុនដែលនៅសល់គាត់ទុកនៅក្នុងក្រុមសន្សំប្រាក់ដើម្បីឲ្យកើនទុនបន្ថែម (ទុកប្រាក់ដើម្បីឲ្យប្រាក់ធ្វើការឲ្យ, ដើម្បីបង្កើនទុនបន្ត) យូរៗទៅទុនទ្រព្យកើនឡើងជាបន្តបន្ទាប់ ។

**ចុះសមាគម លោក-អ្នកដំណើរការ និងប្រមូលទុនទ្រព្យបានកម្រិតណាដែរ?**

**យើងចង់ឱ្យមនុស្សភាគច្រើន ឈប់មានគំនិតផ្តេកផ្តួល**
**ឱ្យរដ្ឋាភិបាលធ្វើនេះធ្វើនោះ ទទួលខុសត្រូវលើយើងតទៅទៀតទៅ**
**យើងត្រូវខំរកស៊ីឱ្យក្លាយជាអ្នកមានតែម្តងទៅ**
**ដើម្បីដោះស្រាយបញ្ហាដោយខ្លួនឯង ។**
**(ដកស្រង់ពីមាគ៌ាមហាសេដ្ឋី ដោយ:** Robert T. Kyosaki **)**

**ភ្នំពេញ, ថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០១១**

**តាត់ សុខ**